# រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះមក ពិនិត្យ សកម្មភាពផលិតកម្មបន្លែរបស់សហគមន៍កសិកម្ម នៅស្រុកសូទ្រនិគម



**ចេញផ្សាយ នៅថ្ងៃចន្ទ  ទី៣១ ខែសីហា ឆ្នាំ២០២០**

**និពន្ធដោយ លោក មែត គឹមម៉ៅ**

ថ្ងៃអាទិត្យ ១២កើត ខែភទ្របទ ឆ្នាំជូត ទោស័កព.ស២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង លោកជំទាវ ព្រមទាំងសហការី បានអញ្ជើញ មកពិនិត្យ សកម្មភាពផលិតកម្មបន្លែរបស់សហគមន៍ កសិកម្មសំរោង មានជ័យ ដែលពិធីនេះបាន រៀបចំធ្វើនៅក្នុងកសិដ្ឋានបន្លែរបស់លោក ឈាវ ហុង នៅភូមិសំរោងត្បូង ឃុំសំរោងស្រុកសូទ្រនិគម។

ជាកិច្ចចាប់ផ្តើម លោកទា គឹមសុទ្ធ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអាន របាយការណ៍ស្តីពីសហគមន៍កសិកម្មដែលបានធ្វើការចុះបញ្ជីនៅមន្ទីរកសិកម្មខេត្តសៀមរាប និងបណ្តុំ អាជីវកម្មកសិកម្ម ដែលគាំទ្រដោយកម្មវិធី ASPIRE នៅខេត្តសៀមរាប ។

